ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*********

# កិច្ចសន្យា

ស្តីពី

ការវិនិយោគទុន លើ ដំណាំកសិកម្ម និង កៅស៊ូ

រវាង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

និង

ក្រុមហ៊ុន CAMBODIA EVERSKY AGRICULTURAL DEVELOPMENT AND INVESTMENT Co., Ltd

កិច្ចសន្យានេះធ្វើឡើងរវាង :

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តំណាងដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានអាស័យដ្ឋានលេខ 200 មហាវិថី ព្រះនរោត្តម ទូរស័ព្ទលេខ ( 855 ) 23.427.320 មានគណនីលេខ 01.063.220 នៅធនាគារពាណិជ្ជកម្មក្រៅប្រទេស ហៅថាភាគី " ក " ។

និង

ក្រុមហ៊ុន CAMBODIA EVERSKY AGRICULTURAL DEVELOPMENT AND INVESTMENT Co., Ltd តំណាងដោយលោក តាំង គាំសាន ឋានៈជានាយកក្រុមហ៊ុន មានស្នាក់ការនៅផ្ទះលេខ 756 ផ្លូវជាតិលេខ 2 សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ( 023 ) 360472 ទូរសារលេខ 023-360472 មានគណនីលេខ 30016190 នៅធនាគារ UNION COMMERCIAL BANK LTD ហៅថាភាគី " ខ " ។

_យោងតាមខ្លឹមសារលិខិតលេខ 316 ចុះថ្ងៃទី 21 ខែ 01 ឆ្នាំ 1997 របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ និងលិខិតជូនដំណឹងលេខ 545 សជណ.កស ចុះថ្ងៃទី 16 ខែមិថុនា ឆ្នាំ 1997 របស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិតលេខ 2021 គ.វ.ក ចុះថ្ងៃទី 23 ខែមិថុនា ឆ្នាំ 1997 ស្តីពីការវិនិយោគលើគំរោងផ្អែកធ្វើចំការដាំដុះកប្បាស បន្លែផ្លែឈើ ម្រេច និងអន្តរដំណាំគ្រប់ប្រភេទ

_ដោយផ្អែកលើច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយមានដូចខាងក្រោមនេះ :

ព្រះរាជាណាចក្រកម្ពុជា CAMBODIA EVER SKY AGRICULTURAL DEVELOPMENT AND INV CO.,LTD

## ប្រការ ១ ៖ កម្មវត្ថុនៃកិច្ចសន្យា

កម្មវត្ថុនៃកិច្ចសន្យានេះគឺភាគី "ក" យល់ព្រមផ្តល់ដីសម្បទានដែលមានផ្ទៃក្រឡាសរុបប្រមាណចំនួន 10000 ហិកតា ស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ( ដូចមានផែនទីជូនភ្ជាប់ ) ជូនទៅភាគី "ខ" កាន់កាប់ប្រើប្រាស់ធ្វើអាជីវកម្មផលិតកម្ម កសិកម្ម ។ ទំហំផ្ទៃដីនេះបានបញ្ជាក់កាន់តែច្បាស់ក្នុងផែនទីចង្អុលទីតាំងដែលភ្ជាប់ជាមួយឧបសម្ព័ន្ធនៃកិច្ចសន្យានេះ ដែលចាប់ពីពេលនេះតទៅហៅថា "ទីតាំង" ។ លើផ្ទៃដីសរុបចំនួន 10000 ហិកតា ខាងលើនេះមាន ៖

1.1 ដីដែលភាគី "ខ" អាចធ្វើអាជីវកម្មដោយផ្ទាល់

1.2 ដីជាកម្មសិទ្ធិរបស់ពលរដ្ឋកាន់កាប់ ដែលក្រុមហ៊ុនអាចសហការធ្វើអាជីវកម្មជាមួយពលរដ្ឋ ដោយមានការយល់ព្រមទាំងសងខាង ។

1.3 ដីជាដីភ្នំ_ដីអាងទឹក និងផ្សេងៗ ដែលត្រូវរក្សាទុកអោយស្ថិតនៅជាលក្ខណៈធម្មជាតិ ។

1.4 ចំនួនផ្ទៃដីដែលមានចែងក្នុងចំនុច 1.1, 1.2, 1.3 ភាគី "ក" និងភាគី "ខ" ត្រូវសហការនិងស្ថាប័នមានសមត្ថកិច្ច សិក្សាស្រាវជ្រាវ អង្កេត និងកំនត់ច្បាស់ចប់សព្វគ្រប់ក្នុងរយៈពេល 3 ខែក្រោយពីកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខា ។ រាល់ការចំណាយលើការអង្កេតនេះជាបន្ទុករបស់ភាគី "ខ" ។

## ប្រការ ២ ៖ អំពីថេរវេលា

2.1 កិច្ចសន្យានេះមានថេរវេលាចំនួន 70 ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យានេះតទៅ ។ នៅពេលផុតរយៈពេលនៃកិច្ចសន្យា ភាគី "ខ" ត្រូវប្រគល់ទីតាំង និង ទ្រព្យសម្បត្តិទាំងអស់ដូចជា ៖ ដើមឈើ, ដំណាំ, សំណង់អាគារ, រោងចក្រ និងសំភារៈបរិក្ខាផ្សេងៗ ។ល។ ជូនភាគី "ក" វិញ ។

2.2 រយៈពេល 01 ឆ្នាំ មុនពេលផុតកំណត់កិច្ចសន្យា ភាគី "ខ" អាចសុំជួលទីតាំងធ្វើវិនិយោគបន្តទៅទៀត ។ ការបន្តអាចធ្វើឡើងបានក្នុងករណីមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដោយយោលទៅតាមការអនុវត្តកន្លងមករបស់ភាគី "ខ" គោលនយោបាយរបស់រាជរដ្ឋាភិបាល នៅពេលនោះនឹងមានការពិភាក្សាដោយមានការឯកភាពពីភាគី "ក" ដែលជាលក្ខខណ្ឌសំរាប់កិច្ចសន្យាថ្មី ។

## ប្រការ ៣ ៖ គោលដៅ និង កម្មវិធីប្រើប្រាស់

គោលដៅ និង កម្មវិធីប្រើប្រាស់ទីតាំងរបស់ភាគី "ខ" គឺការធ្វើផលិតកម្មអាជីវកម្ម ដោយផ្អែកតាមរបាយការណ៍បច្ចេកទេស_សេដ្ឋកិច្ចភ្ជាប់ជាឧបសម្ព័ន្ធ ដែលក្នុងនោះមានគោលសំខាន់ៗដូចតទៅ

CAMBODIA EVER SKY AGRICULTURAL DEVELOPMENT AND INV CO.,LTD

កិច្ចសន្យានេះត្រូវបានចូលជាធរមានចាប់ពីថ្ងៃទី......៣......ខែ......ធ្នូ......ឆ្នាំ 1998 ហើយត្រូវផុតកំណត់នៅ ថ្ងៃទី......៣......ខែ......ធ្នូ......ឆ្នាំ 2068 ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ៣ ខែ ១២ ឆ្នាំ 1998

តំណាងភាគី "ខ"

នាយកក្រុមហ៊ុន.CAMBODIA EVERSKY AGRICULTURAL DEVELOPMENT AND INVESTMENT Co., Ltd

CAMBODIA EVER SKY AGRICULTURAL DEVELOPMENT AND INV CO LTD

តាំង គាំសាន

តំណាងភាគី "ក"

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ឈា_សុខ

<u>កន្លែងតំកល់ឯកសារ</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងឧស្សាហកម្ម
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពង់ធំ
- មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ
- ភាគី " ក "
- ភាគី " ខ "
- កាលប្បវត្តិ_ឯកសារ

# ផែនទីកំណត់តំបន់

## ក្នុងដីសម្បទានរបស់ក្រុមហ៊ុន

## CAMBODIA EVER SKY AGRICULTUREAL DEVELOPMENT AND INVESTMENT LTD.

## ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកសន្ទុកខេត្តកំពង់ធំ

មាត្រដ្ឋាន ១ / ៥០ ០០០




ក្រុមហ៊ុន CAMBODIA EVER SKY AGRICULTUREAL DEVELOPMENT AND INVESTMENT LTD

CAMBODIA FIRST INTERNATIONAL COMPANY LIMITED

CHIA SIN KEN INVESTMENT COMPANY LIMITED

CAMBODIA EVER SKY GROUP COMPANY LIMITED